**សេចក្តីថ្លែងការរបស់ដៃគូអភិវឌ្ឍន៍**

**ស្តីអំពីផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ**

**ថ្លែងដោយ លោកស្រី អាណែត ឌីកសុន នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា**

**នៅក្នុងកិច្ចប្រជុំលើកទី ១៩ របស់គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍**

**ភ្នំពេញ  ថ្ងៃ ទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២**

ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម លោកជំទាវ លោក និង លោកស្រី

ដៃគូអភិវឌ្ឍន៍សូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជាចំពោះការអនុវត្តន៏ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៩-២០១៣ ។ ប្រទេសកម្ពុជាបានជំនះដោយជោគជ័យលើការលំបាកនានា ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៩ និងគ្រោះទឹកជំនន់ឆ្នាំ២០១១។ ទោះស្ថិតក្នុងស្ថានភាពដ៏លំបាកយ៉ាងនេះក៏ដោយ កម្ពុជាបានពុះពាររក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសូចនាករសំខាន់ៗក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាកំពុងតំរង់ទិសកសាងគ្រឹះចាំបាច់នានា ដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានទស្សនៈវិស័យចង់ប្រែក្លាយកម្ពុជាឱ្យទៅជាសង្គមមួយ ដែលរុងរឿងមាន សេដ្ឋកិច្ចកាន់តែប្រសើរឡើងដោយពិធកម្ម និងអាចទប់ទល់ទៅនឹងការប្រែប្រួលបញ្ហាសកលនានា ហើយប្រជាពលរដ្ឋគ្រប់ៗរូប បានទទួលនូវកាលានុវត្តភាពប្រកបដោយសមធម៌។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិថ្មីនឹងមានតួនាទីគន្លឹះក្នុងការកសាងគ្រឹះ នានាដើម្បីឱ្យរាជរដ្ឋាភិបាលកម្ពុជាសំរេចបាននូវទស្សនៈវិស័យ ដែលគួរឱ្យកោតសរសើរបែបនេះ ហើយដៃគូអភិវឌ្ឍន៍ត្រៀមខ្លួនជាស្រេចក្នុងការជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ។

ដើម្បីឈានទៅសម្រេចបានឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យម វានឹងទាមទារឱ្យផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិថ្មីមានភាពបត់បែនដើម្បីឱ្យផលពីកិច្ចអភិវឌ្ឍនានាបានកាន់តែច្រើនឡើង កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈនានា កាន់តែលឿន កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ហើយប្រជាជនកាន់តែច្រើនបានទទួលផល ព្រមទាំងបង្កើនប្រសិទ្ធិភាពការងារ ។ ដើម្បីឱ្យសម្រេចបានគោលដៅនេះ ដៃគូរអភិវឌ្ឍន៍សូមស្នើយោបល់ចំនួន ៥ សម្រាប់រាជរដ្ឋាភិបាលកម្ពុជាពិចារណា។

**១. ទី១ គឺការរៀបរៀងតាក់តែង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គួរមានការចូលរួមឱ្យបានទូលំទូលាយ ដើម្បីបង្កើនភាពស៊ីសង្វាក់គ្នារវាង ក្រសួង-ស្ថាប័ននិងភាគីនានាដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ ។ ការធ្វើដូច្នេះនឹងជួយបង្កើនប្រសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍។**

- គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវមានការប្តេជាចិត្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។
**យើងសូមស្នើរាជរដ្ឋាភិបាលកម្ពុជាឱ្យកំណត់ផែនទីបង្ហាញផ្លូវដ៏ច្បាស់លាស់មួយសំរាប់តាក់តែង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលរដ្ឋាភិបាលទាំងមូល និងភាគីនានាដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍អាចចូលរួមយ៉ាងសកម្ម ។**

**២. ទី២ គឺការបង្កើនល្បឿនកំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈនានាឱ្យប្រកបដោយគុណភាពខ្ពស់ដល់ប្រជាពលរដ្ឋ ។**

- ប្រទេសកម្ពុជាកំពុងស្ថិតលើគន្លងត្រឹមត្រូវដើម្បីឈានទៅសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរបស់ខ្លួនស្ទើរតែទាំងអស់ ។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងទទួលជោគជ័យយ៉ាងខ្លាំងពីកំណែទម្រង់ជាមូលដ្ឋាននានាក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ ដែលតាមរយៈកំណែទម្រង់ទាំងនេះ ប្រជាពលរដ្ឋបានទទួលសេវាជាច្រើន ហើយជាលទ្ធផលអត្រាមរណភាពមាតា និងកុមារបានកាត់បន្ថយយ៉ាងច្រើន កុមារកម្ពុជាបានចុះឈ្មោះចូលរៀនកំរិតបឋមសិក្សា។ ប៉ុន្តែ អត្រាមរណភាពទារក និងអត្រាបោះបង់ការសិក្សានៅកំរិតមធ្យមសិក្សា នៅតែមានកំរិតខ្ពស់នៅឡើយ ដែលនេះបញ្ជាក់ថា គុណភាពនៃសេវាកម្មទាំងនេះនៅតែជាបញ្ហាដដែល ។ **បច្ចុប្បន្ននេះ បញ្ហាប្រឈមជាគន្លឹះគឺ ការអនុវត្តន៍កំណែទម្រង់ស៊ីជម្រៅដើម្បីលើកកម្ពស់គុណភាព នៃសេវាកម្មទាំងនេះ ។ កិច្ចការនេះទាមទារឱ្យពង្រឹងការត្រួតពិនិត្យ និងគណនេយ្យភាពក្នុងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីធានាគុណភាពនៃសេវាកម្មទាំងនេះ ។**
  សូចនាករសំខាន់មួយដែលទំនងជាមិនអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស គឺបញ្ហាកង្វះអាហាររូបត្ថម្ភ ។ **យើងសូមស្នើរាជរដ្ឋាភិបាលកម្ពុជា កែលំអផែនការសកម្មភាពពហុវិស័យ និងការសម្របសម្រួល ព្រមទាំងកំណត់គោលដៅតាមវិស័យនីមួយៗដើម្បីលើកកម្ពស់អាហាររូបត្ថម្ភ និងអនាម័យ ។**
- ដូចបានកត់សំគាល់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (នៅទំព័រ ២៤) ទោះបីមានភាពជឿនលឿនក្នុងការកែសម្រួលនិងសុខដុមភាវូបនីយកម្មក៏ដោយ ក៏ការអនុវត្តន៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតែប្រឈមនឹងបញ្ហាមួយចំនួន។ **យើងសូមគូសបញ្ជាក់ពីសារៈសំខាន់នៃការចូលរួមរបស់ក្រសួង-ស្ថាប័ននានាក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងសារៈសំខាន់នៃទំនាក់ទំនង រវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កំណែទម្រង់រដ្ឋបាល សាធារណៈ ។ កិច្ចការមួយទៀតដែលសំខាន់ដែរនោះគឺ គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ/ក្រសួងមហាផ្ទៃ គួរបង្កើនកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីអនុញ្ញាត្តិឱ្យប្រជាពលរដ្ឋ ចូលរួមក្នុងដំណើរការវិមជ្ឈការនានា។**
- កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ប្រព័ន្ធតុលាការ គឺជាកំណែទម្រង់គន្លឹះពីរមានវឌ្ឍនភាពតិចតួចនៅឡើយដូចបានកត់សំគាល់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ អាស្រ័យហេតុនេះ **យើងសូមស្នើឱ្យមានការអនុវត្តសមាសភាគគន្លឹះនានាក្នុងយុទ្ធសាស្ត្រកំណែទំរង់រដ្ឋបាលសាធារណៈ ជាពិសេសបញ្ហាជុំវិញកំណែទំរង់រដ្ឋបាលសាធារណៈ / បៀវត្ស និងជំរុញកំណែទំរង់ប្រព័ន្ធតុលាការ ។**

**៣. ទី៣ គឺកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងបានផលដល់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីធានាថា ផលនៃកិច្ចអភិវឌ្ឍន៍ត្រូវបានបែងចែកជូនប្រជាជនទាំងអស់ និងមនុស្សជំនាន់ក្រោយៗទៀត ។**

- បញ្ហាប្រឈមសំខាន់សំរាប់ប្រទេសកម្ពុជាក្នុងដំណើរឆ្ពោះទៅកាន់ឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យមគឺ ការធ្វើឱ្យកំណើនសេដ្ឋកិច្ចប្រកបដោយពិធកម្ម និរន្តរភាព និងបានផលដល់ប្រជាពលរដ្ឋគ្រប់រូប ។ ដើម្បីសំរេចគោលដៅនេះ យើងសូមផ្តល់យោបល់ជូន រាជរដ្ឋាភិបាលកម្ពុជា **ឱ្យកែលំអបរិយាកាស ធ្វើយ៉ាងណាឱ្យអំណោយផលដល់ការកែឆ្នៃផលិតផលកសិកម្ម និងជំរុញកំណើនក្នុងវិស័យកម្មន្តសាល តាមរយៈការធ្វើឱ្យបរិយាកាសធុរកិច្ចប្រសើរឡើង បង្កើនជំនាញកំលាំងពលកម្ម និងកែលំអប្រព័ន្ធគមនាគមន៍ពាណិជ្ជកម្ម ។ ក្នុងន័យនេះ តម្រូវឱ្យមានទំនាក់ទំនងរវាងវិស័យឯកជន និងអ្នករៀបរៀងគោលនយោបាយជាប្រចាំ និងមានប្រសិទ្ធិភាព ។**
- ការលើកកំពស់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងបានផលដល់ប្រជាពលរដ្ឋគ្រប់រូប ឱ្យបានកាន់តែល្អជាងមុន តំរូវឱ្យ**ពង្រឹងគោលនយោបាយអភិវឌ្ឍន៍ដីធ្លី ការគ្រប់គ្រងជីវរដ្ឋ ការចុះបញ្ជី ការតាំងទីលំនៅថ្មី និងផែនការរៀបចំផែនការទីក្រុង ព្រមទាំងមានការគិតគូរដល់ពិការភាព យេនឌ័រ បទដ្ឋាននិយ័ត្តកម្មការងារ និងកិច្ចការគាំពារសង្គមផងដែរ ។** កិច្ច**ការទាំងនេះ នឹងតម្រូវឱ្យមានការសំរបសំរួល និងការពង្រឹងការអនុវត្តជាលក្ខណៈអន្តរក្រសួងធំធេងជាងមុន។ ការធានាឱ្យមានការ ប្រើប្រាស់ធនធានធម្មជាតិថ្នាក់ជាតិ និងថ្នាក់តំបន់ប្រកបដោយនិរន្តរភាព និងការដាក់ឱ្យមានគោលនយោបាយ ដែលជំរុញការវិនិយោគឯកជន និងសាធារណៈឆ្ពោះទៅកាន់មាគ៌ារអភិវឌ្ឍន៍ ”កំណើនបៃតង” គឺជាកិច្ចការដ៏សំខាន់ផងដែរ ។**

**៤. ទី៤ គឺ ពង្រឹងកិច្ចការត្រួតពិនិត្យ និងវាយតំលៃ ដោយប្រើលទ្ធផលល្អៗដែលបានធ្វើកន្លងមក ដើម្បីកែលំអការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។**

- ចំនុចល្អមួយក្នុងចំនុចល្អជាច្រើនក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ គឺសូចនាករស្នូលដែលអនុញ្ញាត្តឱ្យរាជរដ្ឋាភិបាលកម្ពុជាតាមដានវឌ្ឍនភាពក្នុងការអនុវត្តផែនការនេះ។ **ដៃគូអភិវឌ្ឍន៍សង្ឃឹមថា ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតំលៃនឹងមានការកែលំអបន្ថែមទៀតនៅពេលតាក់តែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី។ យើងសូមស្នើ រាជរដ្ឋាភិបាលកម្ពុជាឱ្យរៀបរៀងសូចនាករដែលឆ្លុះបញ្ចាំងពីលទ្ធផលនៃការងារ ហើយភ្ជាប់សូចនាករទាំងនោះទៅនឹងសូចនាករត្រួតពិនិត្យរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្នុងគោលបំណងដើម្បីកែលំអការអនុវត្តនិងការតាមដានត្រួតពិនិត្យ។ ដោយសារ ការរៀបចំសូចនាករពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ច មានបញ្ហាលំបាកច្រើន ដៃគូអភិវឌ្ឍន៍ មានបំណងផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីរៀបរៀងសូចនាករទាំងនេះ ។**

**៥. ចំណុចចុងក្រោយ គឺការផ្សារភ្ជាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទៅនឹងកម្មវិធី និងថវិការរបស់ក្រសួង-ស្ថាប័ននានា ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្ត ។**

- ដើម្បីសម្រេចគោលដៅដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ **វាជាកិច្ចការចាំបាច់ដែលតម្រូវឱ្យមានការផ្សារភ្ជាប់ឱ្យច្បាស់លាស់និងដោយផ្ទាល់រវាងសកម្មភាពដែលមាន ចែងក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង អាទិភាពដែលកំណត់ក្នុងកម្មវិធី និងថវិការបស់ក្រសួង-ស្ថាប័ននានា ។**

មុននឹងបញ្ចប់ យើងសូមកោតសរសើរចំពោះវឌ្ឍនភាពនានាដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានកន្លងមក និងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ពិនិត្យពិចារណាសំណើដែលបានលើកឡើងខាងលើ។ ជាសរុបយើងសូមស្នើរាជរដ្ឋាភិបាលកម្ពុជា រៀបចំចងក្រង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយមានការចូលរួម ពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធទាំងអស់ បង្កើនល្បឿនកំណែទំរង់នានា លើកកំពស់កំណើនសេដ្ឋកិច្ចប្រកបនិរន្តរភាព និងបានផលដល់ប្រជាពលរដ្ឋគ្រប់រូបពង្រឹងកិច្ចការតាមដានត្រួតពិនិត្យ និងផ្សារភ្ជាប់កម្មវិធីនិងថវិការបស់ក្រសួង-ស្ថាប័ននានាអនុលោមតាមអាទិភាពចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតដើម្បីបង្កើនប្រសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍។ កិច្ចការសំខាន់ៗទាំងនេះនឹងជួយប្រទេសកម្ពុជាឱ្យមានជំហរដ៏រឹងមាំដើម្បីឈានទៅសំរេចបានឋានៈជាប្រទេសដែលមានប្រាក់ចំណូលមធ្យម។